## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រដ្ឋបាលជលផល

# ឯកសារបណ្តុះបណ្តាលស្តីពីសហគ្រប់គ្រងធនធានជលផល

***គម្រោងគ្រប់គ្រងធនធានទឹកចម្រុះ ទន្លេមេគង្គ ដំណាក់កាលទី៣ (M-IWRMP-III)***

*សមាសភាគទី១៖ ការគាំទ្រដល់ការគ្រប់គ្រងធនធានជលផលនៅភូមិភាគឦសាននៃប្រទេសកម្ពុជា*

***វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាបនៃរដ្ឋបាលជលផល***
***២០១៨***

២

# សហគ្រប់គ្រងធនធានជលផល
# ឯកសារទី២ : ការពង្រឹងសហគមន៍នេសាទ



គម្រោងគ្រប់គ្រងធនធានទឹកចម្រុះ ទន្លេមេគង្គ ដំណាក់កាលទី៣ ( M-IWRMP-III )

សមាសភាគទី១៖ ការគាំទ្រដល់ការគ្រប់គ្រងធនធានជលផលនៅភូមិភាគឦសាននៃប្រទេសកម្ពុជា

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប នៃរដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ១. តើសហគ្រប់គ្រងធនធានជលផលមានន័យដូចម្តេច?

សហគ្រប់គ្រង សំដៅដល់ភាពជាដៃគូរវាង សហគមន៍នេសាទ ស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត (ដូចជា៖ អ្នកលក់ត្រី អ្នកជំនួញ អង្គការមិនមែនរដ្ឋាភិបាល ។ល។) និងការបែងចែកសិទ្ធិរួមទាំងការទទួលខុសត្រូវក្នុងការគ្រប់គ្រងធនធានជលផល។

ចំពោះកិច្ចសហការរវាងស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល និងប្រជានេសាទនៅមូលដ្ឋាន ចាំបាច់ត្រូវបង្កើតសហគមន៍នេសាទ។

តាមរយៈកិច្ចពិគ្រោះយោបល់ និងការចរចា រដ្ឋបាលជលផល និងសហគមន៍នេសាទត្រូវបង្កើតកិច្ចព្រមព្រៀងដូចជា៖ កន្លែងនេសាទសហគមន៍ តួនាទី និងភារកិច្ចរបស់ភាគីពាក់ព័ន្ធ និងសិទ្ធិក្នុងការគ្រប់គ្រងធនធានជលផល។



# ១. តើសហគ្រប់គ្រងធនធានជលផលមានន័យដូចម្តេច? (ត)

សហគ្រប់គ្រងធនធានជលផលរួមមាន៖

- សមាជិកភាពប្រកបដោយសមធម៌៖ យុត្តិធម៌ ស្មើភាព និងបើកទូលាយចំពោះប្រជាពលរដ្ឋទូទៅ (ស្ត្រី និងជនជាតិដើមភាគតិចត្រូវបានលើកទឹកចិត្ត ឱ្យចូលជាសមាជិកសហគមន៍នេសាទ)
- រួបរួមគ្នា និងសហប្រតិបត្តិការ៖ ធ្វើការរួមគ្នាដើម្បីសម្រេចគោលដៅរួមមួយ
- បែងចែកសិទ្ធិអំណាច(ការទទួលខុសត្រូវ និងសិទ្ធិអំណាច)៖ ទទួលខុសត្រូវរួមគ្នា លើការសម្រេចចិត្ត
- មានគោលដៅច្បាស់លាស់
- កិច្ចព្រមព្រៀង៖ ការរៀបចំរវាងភាគីពាក់ព័ន្ធចំពោះសកម្មភាពជាក់លាក់។



## ២. តួនាទី និងការទទួលខុសត្រូវរបស់ប្រជានេសាទនៅក្នុងសហគមន៍នេសាទ

សមាជិកនៃសហគមន៍នេសាទមួយមានសិទ្ធិក្នុងការៈ

- ចូលរួមប្រជុំបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតក្នុងគណៈកម្មការសហគមន៍នេសាទ
- ស្នើឱ្យមានកិច្ចប្រជុំ និងលើកឡើងនូវបញ្ហាទាក់ទងនឹងជលផល និងពិភាក្សារកដំណោះស្រាយ
- នេសាទជាលក្ខណៈគ្រួសារ ដោយគោរពតាមច្បាប់ និងលិខិតបទដ្ឋានដែលទាក់ទងទៅនឹងវិស័យជលផល លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ
- ចូលរួមគ្រប់សកម្មភាពរបស់សហគមន៍នេសាទ
- តវ៉ាចំពោះបញ្ហាទាំងឡាយដែលប៉ះពាល់ដល់ផលប្រយោជន៍សហគមន៍នេសាទ ទៅក្រុមប្រឹក្សា ឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន រដ្ឋបាលជលផល និងសមត្ថកិច្ចពាក់ព័ន្ធនានា។









## ៣. គោលការណ៍គ្រប់គ្រងធនធានជលផលផ្ដោតលើប្រព័ន្ធអេកូឡូស៊ី

សហគ្រប់គ្រងធនធានជលផលដែលល្អរួមមាន៖ តុល្យភាពរវាងសមាសធាតុចំនួនបីគឺបរិស្ថាន សង្គម( សុខុមាលភាព ) និងអភិបាលកិច្ច។

- **បរិស្ថានល្អ៖** មានពូជត្រីច្រើនប្រភេទ ផលត្រីសម្បូរ មិនធ្វើឱ្យខូចខាតជម្រកត្រី និងទឹកមានគុណភាព
- **សង្គម( សុខុមាលភាព )៖** ប្រជាពលរដ្ឋមានស្តង់ដាររស់នៅល្អ ( ប្រាក់ចំណូលសមរម្យ ) សុវត្ថិភាពស្បៀង ទំនាក់ទំនងសង្គមមានភាពប្រសើរឡើង និងជានាសុវត្ថិភាព
- **អភិបាលកិច្ចល្អ៖** សំដៅដល់ការចូលរួម សិទ្ធិជាផ្លូវការ សមធម៌ យន្តការរៀបចំផែនការ និងការអនុវត្ត ការគោរពនិងការពង្រឹងការអនុវត្តន៍ច្បាប់។

វាជាវិធីសាស្ត្រមួយ ដែលគិតគូរទៅលើធាតុសំខាន់ៗនៅក្នុងប្រព័ន្ធអេកូឡូស៊ី និងគិតគូរពីផលប្រយោជន៍សេដ្ឋកិច្ចសង្គមបានមកតាមរយៈការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។



## ៤. ការដោះស្រាយវិវាទ

នៅក្នុងផែនការគ្រប់គ្រងត្រូវគិតគូរអំពីការដោះស្រាយវិវាទ៖

- វិវាទក្នុងសហគមន៍នេសាទ
- វិវាទរវាងសមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋ
- វិវាទរវាងសហគមន៍នេសាទ និងអ្នកមកពីខាងក្រៅ។

យន្តការដោះស្រាយវិវាទ គួររួមបញ្ចូលនូវ៖

- ការដោះស្រាយវិវាទដំបូង (ពេលដែលភាគីទាំងអស់ត្រៀមនឹងដោះស្រាយ)
- វិវាទធំៗ (ពេលដែលភាគីទាំងអស់ទំនងជាមិនឯកភាពគ្នា)។

ក្នុងករណីនីមួយៗ គួរបញ្ចូលនូវ៖

- អ្នកណា ជាអ្នកជួយដោះស្រាយ
- អ្នកណា ជាអ្នកសម្រេចក្នុងករណីដែលមិនមានការឯកភាពគ្នា។



## ៥. កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ រវាងសហគមន៍នេសាទ និងរដ្ឋបាលជលផល ទទួលស្គាល់ និងធានាសិទ្ធិរបស់សហគមន៍នេសាទចំពោះផែនទីដែលបានកំណត់។

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ គួរបញ្ចូលចំណុចសំខាន់ៗ៖

- ភាគីហត្ថលេខី និងតួនាទី និងការទទួលខុសត្រូវរបស់ភាគីនីមួយៗ
- ទីកន្លែង និងទំហំដែននេសាទ
- លក្ខខណ្ឌ និងពេលវេលានៃការគ្រប់គ្រង និងការប្រើប្រាស់ឧបករណ៍នេសាទ
- លក្ខខណ្ឌនៃវិសោធនកម្ម និងការបញ្ចប់កិច្ចព្រមព្រៀង។



## ៦. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គោលបំណងនៃការរៀបចំផែនការគឺកំណត់៖

- គោលដៅ គោលបំណង យុទ្ធសាស្ត្រ និងសកម្មភាព
- តួនាទី និងភារកិច្ចរបស់សហគមន៍នេសាទ និងរដ្ឋបាលជលផល ព្រមទាំងអ្នកពាក់ព័ន្ធ។

នៅក្នុងផែនការគួរបញ្ចូល៖

- បញ្ហាបរិស្ថាន (ឧទា. ផលប៉ះពាល់លើជម្រកពងកូនចំពោះប្រភេទត្រីខ្លះ)
- បញ្ហាសង្គម (ឧទា. ការវិវាទ សុខភាព សុវត្ថិភាព និងការកែច្នៃផលនេសាទ)
- បញ្ហាអភិបាលកិច្ច (ឧទា. ដំណើរការពិគ្រោះយោបល់ និងការចូលរួមរបស់ស្ត្រី)។



## ៦.១ មាតិកាផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
## ៦.១.១ សំណួរនានាទាក់ទងនឹងការរៀបចំផែនការគ្រប់គ្រង

ខ្លឹមសារមានក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ គួរឆ្លើយនឹងសំណួរខាងក្រោម៖

- តើមានគោលដៅ និងគោលបំណងអ្វីខ្លះ ដែលចង់សម្រេចឱ្យបាន?
- តើមានសកម្មភាពចម្បងៗអ្វីខ្លះ ដើម្បីសម្រេចគោលដៅ និងគោលបំណង?
- តើសង្ឃឹមថានឹងទទួលបានលទ្ធផលអ្វីខ្លះ?
- តើត្រូវការរយៈពេលប៉ុន្មាន ក្នុងការអនុវត្តយុទ្ធ-សាស្ត្រនេះ?
- តើអ្នកណាខ្លះជាអ្នកអនុវត្តសកម្មភាព?
- តើអ្នកណាជាអ្នកទទួលខុសត្រូវអនុវត្តសកម្មភាព?
- តើមានតម្រូវការថវិកាប៉ុន្មាន និងបានមកពីណា?



## ៦.១.២ សកម្មភាពយេនឌ័រក្នុងផែនការគ្រប់គ្រង

សកម្មភាពដែលទាក់ទងនឹងយេនឌ័រគួរត្រូវបានបញ្ចូលក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍មានដូចជា៖

- គោលដៅ និងគោលបំណងដែលឆ្លើយតបនឹងតម្រូវការរបស់បុរស និងស្ត្រី
- ការវិនិយោគលើការកែលម្អបច្ចេកទេសកែច្នៃផលនេសាទដែលក្រុមស្ត្រីត្រូវការ
- សកម្មភាពនានា សំដៅលើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្នុងគណៈកម្មការសហគមន៍នេសាទ
- ការបណ្តុះបណ្តាលដែលលើកកម្ពស់សមធម៌ និងសមភាពស្ត្រី ក្នុងវិស័យជលផល

កិច្ចប្រជុំជាមួយក្រុមស្ត្រីគួរត្រូវរៀបចំដោយឡែក ដើម្បីកំណត់បញ្ហាតម្រូវការ និងឱកាសរបស់ស្ត្រី និងបញ្ចូលបញ្ហា តម្រូវការ និងឱកាសទាំងនោះទៅក្នុងផែនការគ្រប់គ្រង។



## ៦.២ ដំណើរការនៃការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
## ៦.២.១ ការកំណត់ និងចាត់អាទិភាព បញ្ហា និងគោលបំណង
### ៦.២.១.១ ការកំណត់បញ្ហា ឬការគំរាមកំហែង

ការកំណត់បញ្ហា និងការគំរាមកំហែងទាក់ទងនឹងវិស័យជលផល។

បញ្ហានិងការគំរាមកំហែងរួមមាន៖

- **បរិស្ថាន៖** សំដៅលើកិច្ចការពារ និងស្តារជម្រកត្រី កាត់បន្ថយការបំពុលទឹក ការគ្រប់គ្រងកាកសំណល់ និងធនធានជលផល
- **សង្គម៖** សំដៅលើសុវត្ថិភាពស្បៀង ការចិញ្ចឹមជីវិតមាននិរន្តរភាព និងហេដ្ឋារចនាសម្ព័ន្ធជនបទ
- **អភិបាលកិច្ច៖** សំដៅលើការចូលរួមការផ្តល់អំណាច និងពង្រឹងស្ថាប័នជាដើម។

ការកំណត់បញ្ហាមិនគ្រាន់តែពិនិត្យលើវិស័យជលផលប៉ុណ្ណោះទេ តែត្រូវពិនិត្យទៅលើការអភិវឌ្ឍសហគមន៍ របរចិញ្ចឹមជីវិត សុវត្ថិភាពស្បៀង អភិបាលកិច្ច សេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន។



## ៦.២.១.២ ការចាត់អាទិភាពបញ្ហា និងការគំរាមកំហែង

បន្ទាប់ពីកំណត់បញ្ហា ត្រូវចាត់អាទិភាពបញ្ហា មានន័យថាជ្រើសរើសចំនួនសកម្មភាពសំខាន់ៗ រួចកំណត់សកម្មភាពដែលសំខាន់ជាងគេ និងសកម្មភាពបន្តបន្ទាប់ៗល។

ការងារនេះកំណត់អាទិភាព បញ្ហាដែលមានទំនាក់ទំនងជាមួយនឹងសកម្មភាព។



## ៦.២.១.៣ ការកំណត់តម្រូវការ និងចាត់អាទិភាព

គណៈកម្មការសហគមន៍នេសាទ ត្រូវសម្របសម្រួលជាមួយសមាជិក ក្នុងការកំណត់តម្រូវការ និងចាត់អាទិភាព ដែលឆ្លើយតបនឹងបញ្ហា និងការគំរាមកំហែងដែលរកឃើញខាងលើ។ នេះជាផ្នែកមួយសំខាន់ ពីព្រោះវានឹងកំណត់នូវសកម្មភាពចម្បងៗដែលឆ្លើយតបនឹងតម្រូវការ។




**ការកំណត់តម្រូវការ ដែលទាក់ទងជាមួយបញ្ហា និងការគំរាមកំហែង៖** បញ្ជីតម្រូវការត្រូវរៀបចំឱ្យច្បាស់លាស់ និងកំណត់ចំនួនបាន ដោយផ្តោតលើតម្រូវការណាដែលគណៈកម្មការ និងសហគមន៍នេសាទអាចដោះស្រាយបាន។

## ៦.២.១.៣ ការកំណត់តម្រូវការ និងចាត់អាទិភាព (ត)

ការចាត់អាទិភាពតម្រូវការដែលទាក់ទងនឹងបញ្ហា និងការគំរាមកំហែង៖

បន្ទាប់ពីកំណត់តម្រូវការរួច ត្រូវចាត់អាទិភាព។ នៅពេលចាត់អាទិភាព ត្រូវរកតម្រូវការសំខាន់ដែលចាំបាច់ ចម្បង និងបន្ទាន់ជាងគេ និងជ្រើសរើសជាបន្តបន្ទាប់ តាមលំដាប់លំដោយ ដើម្បីឱ្យសហគមន៍នេសាទឆ្លើយតបនឹងតម្រូវការ និងទទួលបានលទ្ធផលល្អ។



## ៦.២.១.៤ កំណត់គោលដៅសម្រាប់ផែនការគ្រប់គ្រងជលផល

គោលដៅ គឺជាស្ថានភាពដែលអ្នកពាក់ព័ន្ធរួមគ្នាដើម្បីសម្រេចនូវអ្វីដែលចង់បាន។

ឧទា.៖ គោលដៅមួយ ឬច្រើនត្រូវបានរៀបចំឱ្យមានទំនាក់ទំនងជាមួយបញ្ហា និងការគំរាមកំហែងដែលបានរកឃើញ ហើយគោលដៅត្រូវរៀបចំឱ្យស្របតាមសមាសភាគទាំង៣ ដើម្បីសម្រេចនូវអ្វីដែលចង់បាន ១) គោលដៅផ្នែកបរិស្ថាន ២) គោលដៅផ្នែកសង្គម និង៣) គោលដៅផ្នែកអភិបាលកិច្ច



## ៦.២.២ ការបង្កើតផែនការ
### ៦.២.២.១ កំណត់គោលបំណង

គោលបំណងត្រូវបានរៀបចំឡើង យោងទៅតាមបញ្ហា និងគោលដៅ បើសិនជាគេកំណត់បានបញ្ហាជាក់លាក់ នោះវាមានភាពងាយស្រួលក្នុងការបង្កើតគោលបំណង។ គេត្រូវរៀបរាប់អំពីអ្វីដែលត្រូវធ្វើឱ្យសម្រេច។ ឧទា. ខាងក្រោមបង្ហាញពីមែកធាងនៃគោលបំណង។

ទស្សនៈវិស័យ គោលដៅ គោលបំណង



## ៦.២.៣ ការអនុវត្តផែនការ
### ៦.២.៣.១ ការកំណត់វិធានការគ្រប់គ្រង

វិធានការគ្រប់គ្រងរួមបញ្ចូលទាំងទិដ្ឋភាពបច្ចេកទេស ដូចជា៖ ការកំណត់ចំពោះប្រភេទឧបករណ៍នេសាទហាមឃាត់ ការពង្រឹងរដូវបិទនេសាទ និងការពាររដូវពងកូន។

- លទ្ធផលរំពឹងទុក (បង្កើតអ្វី ឬមានអ្វីដែលផ្លាស់ប្តូរ)
- ពេលវេលា (តើយុទ្ធសាស្ត្រ ត្រូវបានអនុវត្តក្នុងអំឡុងពេលណា?)
- អ្នកអនុវត្តសកម្មភាព (តម្រូវការកិច្ចសហប្រតិបត្តិការ ក្នុងការអនុវត្តសកម្មភាព)
- អ្នកទទួលខុសត្រូវឬស្ថាប័នអនុវត្តសកម្មភាព (អ្នកទទួលខុសត្រូវ ចំពោះការអនុវត្ត)
- តម្រូវការ និងប្រភពហិរញ្ញវត្ថុ។



# ៦.២.៣ ការអនុវត្តផែនការ
# ៦.២.៣.១ ការកំណត់វិធានការគ្រប់គ្រង (ត)

| គោលបំណង | សូចនាករ | វិធានការ |
| --- | --- | --- |
| កាត់បន្ថយ មូលហេតុត្រីងាប់ ឧទា. អាងស្តុកទឹក | បន្ថយកន្លែងស្ទាក់ទឹកចំនួន ២០% ក្នុងពេល ៣ឆ្នាំ | នៅឆ្នាំទី១ កំណត់ កន្លែងស្ទាក់ទឹក ដែលបង្កផលប៉ះពាល់ និងរកជម្រើសរំលាយចោល |
| អភិរក្សកន្លែងត្រីពងកូន | ហាមឃាត់ការធ្វើនេសាទនៅកន្លែងចំនួន ២ ដែលត្រីធ្លាប់ពងកូន | កំណត់តំបន់គោលដៅចំនួន២ នៅរដូវ បិទនេសាទ និងបង្កើតក្រុមល្បាត១ |
| ធ្វើឱ្យត្រីមានទំហំធំ | កាត់បន្ថយ មងក្រឡាញឹក ៣០% ក្នុងពេល៣ឆ្នាំ | កំណត់បានទំហំក្រឡាមងដែលហាមឃាត់ និងរកវិធីពង្រឹងការអនុវត្តច្បាប់ |
| ធ្វើឱ្យប្រសើរឡើងការលក់ដូរផលនេសាទ | ឆ្នាំក្រោយ សហគមន៍នេសាទទិញបានម៉ូតូ១ ដឹកត្រីលក់នៅផ្សារ | ប្រមូលថវិកាទិញម៉ូតូ១គ្រឿង |
| កាត់បន្ថយសមត្ថភាពនេសាទ | អ្នកនេសាទស្ម័គ្រចិត្ត ៥នាក់ ក្លាយកសិករ ១០០% ក្នុងពេល ៥ឆ្នាំក្រោយទទួលបានដី | កំណត់ទីតាំងដីទុកឱ្យអ្នកស្ម័គ្រចិត្ត ធ្វើរបរកសិកម្ម និងឈប់នេសាទ |
| បង្កើនផលប្រយោជន៍អ្នកនេសាទ | ទិញទូរស័ព្ទ១ទុក ដើម្បីដឹងពីតម្លៃផលនេសាទពីអ្នកលក់ត្រី ៣នាក់ យ៉ាងតិច | ប្រមូលថវិកាទិញទូរសព្ទ១ និងកំណត់ អ្នកទទួលបន្ទុកស្ទង់តម្លៃត្រីប្រចាំថ្ងៃ |
| បង្កើនផលប្រយោជន៍ស្ត្រី | ប្រមូលថវិកាធ្វើរោងឆ្អើត្រីនៅឆ្នាំទី២ | កំណត់ទីតាំង និងតម្លៃ សង់រោងឆ្អើរត្រី និងចងក្រងក្រុម រួចបង់ថវិកា |

## ៦.២.៣.២ ការគោរពច្បាប់ និងពង្រឹងការអនុវត្តច្បាប់

អន្តរាគមន៍ពង្រឹងការអនុវត្តច្បាប់ អាចជាវិធានការទន់ភ្លន់ ឬដាក់ទណ្ឌកម្មធ្ងន់ធ្ងរ។ វិធានការទន់ភ្លន់ ជំរុញការអនុវត្តច្បាប់ដោយស្ម័គ្រចិត្ត យោងតាមលិខិតបទដ្ឋានគតិយុត្ត។

**វិធានការទន់ភ្លន់នេះរួមមាន៖**

- ការបំផុសចលនាក្នុងសង្គម
- ជំរុញបន្តប្រតិបត្តិការអនុវត្តល្អៗ
- ចែករំលែកពត៌មាន អប់រំ និងការចុះដល់មូលដ្ឋាន។

**វិធានការក្តៅអនុវត្តតាមច្បាប់ជាធរមានរួមមាន៖**

- វត្តមាននៃក្រុមអនុវត្តច្បាប់
- សកម្មភាពស្វែងរកចាប់ខ្លួន ប្តឹងជនល្មើស និងដាក់ទណ្ឌកម្មស្របតាមទោសកំហុសដែលបានប្រព្រឹត្តិ
- បដិសេធផលប្រយោជន៍សេដ្ឋកិច្ច ដែលបានមកពីសកម្មភាពល្មើស។



## ៧. ការធ្វើបច្ចុប្បន្នភាពផែនការ

ជារៀងរាល់ឆ្នាំ សហគមន៍នេសាទត្រូវរៀបចំមហាសន្និបាតប្រចាំឆ្នាំ ដើម្បីពិនិត្យឡើងវិញនូវផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍។ ការពិនិត្យឡើងវិញនេះអនុវត្តតាមនីតិវិធីខាងលើ និងពិចារណាលើបញ្ហាជាអាទិភាព គោលដៅ និងសកម្មភាព។ ហិរញ្ញវត្ថុ និងប្រភពក៏ត្រូវពិនិត្យផងដែរ។



## ៧. ការធ្វើបច្ចុប្បន្នភាពផែនការ (ត)

ការគ្រប់គ្រងសហគមន៍នេសាទ គឺជាដំណើរការ ដើម្បីសម្រេចគោលបំណងនានា។

ការតាមដានត្រួតពិនិត្យ ត្រូវធ្វើឡើងដើម្បីកំណត់ថាតើសកម្មភាពបានអនុវត្តតាមការគ្រោងទុកដែរឬទេ? ការវាយតម្លៃ ត្រូវធ្វើឡើងដើម្បីកំណត់ថាតើអ្វីខ្លះដែលជាមេរៀន និងបទពិសោធន៍ពីជោគជ័យ និងបរាជ័យ។

ការវាយតម្លៃរួមមានការពិនិត្យឡើងវិញ និងប៉ាន់ប្រមាណនូវលទ្ធផល ដែលអនុវត្តបាន ដើម្បីជួយសម្រប និងកែលម្អ តាមរយៈការរៀនសូត្រ (ការគ្រប់គ្រងដោយមានភាពបត់បែន)។



## ៨. ប្រភពថវិកា

ភាពគ្រប់គ្រាន់ ភាពទាន់ពេលវេលា ធនធានហិរញ្ញវត្ថុមាននិរន្តរភាពជាកត្តាគន្លឹះ ក្នុងការគាំទ្រការអនុវត្តផែនការគ្រប់គ្រង កន្លែងនេសាទសហគមន៍។ ធនធានហិរញ្ញវត្ថុមាននិរន្តរភាពគួរត្រូវបានគិតគូរតាំងពីដំបូងនៃផែនការ។

គណៈកម្មការសហគមន៍នេសាទត្រូវការធនធានហិរញ្ញវត្ថុ។ ផែនការថវិកាត្រូវរៀបចំឡើងដោយឈរលើមូលដ្ឋាននៃការវាយតម្លៃរាល់ការចំណាយចំពោះសកម្មភាពនានា។

យោងតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ សហគមន៍អាចរកចំណូលពីប្រភពណាមួយ ឬគ្រប់គ្រងថវិកាដោយខ្លួនឯង។ ប្រភពធនធានហិរញ្ញវត្ថុមាននិរន្តរភាពរួមមាន៖

- ភាគទានរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល
- ចំណូលពីទេសចរណ៍ (សំបុត្រចូលទស្សនា និងជិះទូកកំសាន្ត ... )
- ចំណូលស្របច្បាប់ផ្សេងទៀត។